## អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
## អគ្គនាយកដ្ឋានស្រាវជ្រាវ
## នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- កម្ពុជាបាននាំចេញផលិតផលវាយនភណ្ឌ ទៅកាន់ទីផ្សារអាមេរិក ៣០% ទោះបីស្ថិតក្នុងវិបត្តិកូវីដ-១៩ ក្តី
- តើវិស័យអចលនទ្រព្យកម្ពុជាអាចរងប៉ះពាល់ពីសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែនដែរឬទេ ?
- ស្ថាប័នរដ្ឋ និងឯកជនជាង១០ហើយ បានទិញបណ្ណបំណុលក្រុមហ៊ុនអភិវឌ្ឍព្រលានយន្តហោះភ្នំពេញថ្មី
- ការនាំចេញអង្ករកម្ពុជាទៅរុស្ស៊ី និងអ៊ុយក្រែន ពុំទទួលរងផលប៉ះពាល់ឡើយ
- លំហូរចូលFDI កម្ពុជាកើន២២%ត្រឹម ៤,៣៥ពាន់ដុល្លារក្នុងឆ្នាំ២០២១
- សហព័ន្ធឧស្សាហកម្មថៃទាមទារឱ្យរាជរដ្ឋាភិបាលថៃដោះស្រាយលើបញ្ហាខ្វះខាតកម្លាំងពលកម្ម
- ទុនបម្រុងអន្តរជាតិហ្វីលីពីន មានលើសពីគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាអស្ថិរភាពទីផ្សារនានា
- ការនាំចេញវៀតណាមទៅរុស្ស៊ីចាប់ផ្តើមរងប៉ះពាល់ ដោយសារតែទណ្ឌកម្មលោកខាងលិច
- កាលពីខែកុម្ភៈ ចំនួនអ្នកមានការងារធ្វើនៅសហរដ្ឋអាមេរិកបានកើនឡើងចំនួន ៦៧៨ ០០០កន្លែង
- ប្រេងឡើងថ្លៃបានធ្វើឱ្យប៉ះពាល់ដល់ទំនិញជាច្រើនពាន់មុខ
- ប្រទេសចិនប្រកាសប្តេជ្ញាបន្តការបង្ក្រាបលើការអនុវត្តអាជីវកម្មផ្តាច់មុខ
- ធនាគាររុស្ស៊ីប្តូរមកប្រើប្រព័ន្ធកាត UnionPayរបស់ចិន ក្រោយVisa និង MasterCard បិទប្រតិបត្តិការ

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរះ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្ពុជាបាននាំចេញផលិតផលវាយនភណ្ឌ ទៅកាន់ទីផ្សារអាមេរិក ៣០% ទោះបីស្ថិតក្នុងវិបត្តិកូវីដ-១៩ ក្តី



*ដោយ Kampucheathmey*

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បានលើកឡើងថា ការនាំចេញផលិតផលវាយនភណ្ឌរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានចំនួនរហូតដល់ទៅ៣០% ដែលនេះជាចំនួនដ៏ច្រើនមួយ បើប្រៀបធៀបជាមួយនឹងប្រទេសដទៃផ្សេងទៀត បើទោះកំពុងជួបវិបត្តិកូវីដ-១៩ ក្តី។ កំណើននេះ សបញ្ជាក់ពីការសហការគ្នាយ៉ាងល្អ រវាងកម្ពុជា-សហរដ្ឋអាមេរិក។

ភាគីកម្ពុជា ក៏បានកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក បានពង្រឹងកិច្ចសហប្រតិបត្តិការនាំឱ្យមានការវិវត្តន៍រីកចំរើន និងដោះស្រាយនូវបញ្ហាប្រឈមនានាដោយឈរលើស្មារតីរួមគ្នាក្នុងការលើកកម្ពស់សិទ្ធការងារ សេរីភាពអង្គការវិជ្ជាជីវៈ លក្ខខណ្ឌការងារ អនុលោមតាមច្បាប់ស្តីពី ការងារ និងបទដ្ឋានការងារអន្តរជាតិ។ ចំពោះ ការជួញដូរកម្លាំងពលកម្ម ការលុបបំបាត់ពលកម្មកុមារ សុទ្ធតែទទួលបាននូវវឌ្ឍភាពគួរឱ្យកត់សំគាល់ ហើយក្រុមអធិការកិច្ចការងារ កំពុងខិតខំបន្តយុទ្ធនាការអប់រំផ្សព្វផ្សាយដល់សហគ្រាស សិប្បកម្ម និងអាណាព្យាបាលឱ្យយល់ពីច្បាប់ អាចឱ្យប្រើប្រាស់កុមារ លើប្រភេទការងារណា ហើយក្នុងលក្ខខណ្ឌបែបណា។ ចំពោះសហគ្រាស សិប្បកម្ម ដែលមិនអនុលោមតាម ត្រូវដកហូតកុមារចេញពីពលកម្មកុមារបានជាបន្តបន្ទាប់ ក្នុងគោលដៅឈានទៅសម្រេចឱ្យបាននូវផែនការយុទ្ធសាស្ត្រគ្មានពលកម្មកុមារ នាឆ្នាំ ២០២៥។ យើងនឹងបន្តជម្រុញការងារទាំងនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ ធានាបាននូវការការពារ និងលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍ពលករទេសន្តរប្រវេសន៍ ការពារពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬការរើសអើងនៅកន្លែងធ្វើការ, ផ្តល់ជំនួយផ្នែកច្បាប់ និងសុខុមាលភាព, ជួយដល់ពលករ ក្នុងការទទួលបានឯកសារផ្លូវច្បាប់ត្រឹមត្រូវ និងជួយដល់ពលករចំណាកស្រុក ដែលមិនមានឯកសារ, សម្របសម្រួលលទ្ធភាពទទួលបានរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍ផ្សេងៗ ស្របតាមច្បាប់នៃប្រទេសគោលដៅ។

ភាគីទាំងពីរបានសម្តែងនូវមោទភាព ចំពោះវឌ្ឍភាពនៃកិច្ចសហប្រតិបត្តិទាំងនេះ ហើយបានឯកភាពគ្នា ក្នុងការជំរុញការងារទាំងនេះបន្តទៀត ទាំងការរួមគ្នាក្នុងការធ្វើឱ្យកាន់ប្រសើរឡើងនូវការអនុវត្តសិទ្ធសេរីភាពអង្គការវិជ្ជាជីវៈការរៀបចំឱ្យមាន ជាវេទិការចែករំលែកបទពិសោធន៍ និងការសិក្សាសម្រួលដល់ការធ្វើឱ្យនីតិវិធីនានា កាន់តែងាយស្រួលក្នុងការចូលរួមអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធ នឹងវិស័យការងារ កាន់តែប្រសើរ។

កម្ពុជានឹងបន្តជំរុញឱ្យម្ចាស់រោងចក្រ សហគ្រាស ផ្នែកផលិតផលិតផលធ្វើដំណើរ និងកាបូប ចូលជាសមាជិកនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដើម្បីទទួលបាននូវវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ហើយក្រសួងនឹងរៀបចំឱ្យមានជាអធិការកិច្ចរួមគ្នា រវាងអធិការកិច្ចការងារ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។

ចំពោះករណីវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខិតខំឱ្យអស់លទ្ធភាព ក្នុងផ្សះផ្សា និងស្វែងរកដំណោះស្រាយ តាមយន្តការចរចារ ហើយតែងតែអញ្ជើញភាគីវិវាទ ចូលមកជួបចរចារដោះស្រាយដោយសន្តិវិធី ស្របតាមនីតិវិធីច្បាប់ជាធរមាន ហើយក្រសួងរីករាយ ក្នុងការផ្តល់សេវាផ្នែកច្បាប់ជូនដល់ភាគីវិវាទ ដើម្បីធានាបាននូវការការពារតាមផ្លូវច្បាប់ ដែលកន្លងមកក្រសួងបាននិងកំពុងអនុវត្ត ក្នុងការជួយគាំពារដល់កម្មករនិយោជិត ជាពិសេស មេដឹកនាំសហជីព៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ Kampucheathmey ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។*

## បច្ចុប្បន្នភាពពីការនាំចេញអង្ករកម្ពុជាទៅប្រទេសចិន



*ដោយ Kampucheathmey*

សហព័ន្ធស្រូវអង្ករកម្ពុជា និងក្រុមហ៊ុនសាជីវកម្មចិន COFCO បានជួបប្រជុំដើម្បីពិនិត្យមើលលើការងារនាំចេញអង្ករពីកម្ពុជា ទៅប្រទេសចិន។ កិច្ចប្រជុំនេះដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃក្រុមហ៊ុនហ្គ្រីនត្រេដ នៃក្រសួងពាណិជ្ជកម្ម និងអគ្គនាយកក្រុមហ៊ុនសាជីវកម្មចិន COFCO និងចូលរួមតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា។ តាមរយៈកិច្ចប្រជុំនេះ បានបង្ហាញ លទ្ធផលដែលសម្រេចបានលើការអនុវត្តបានទាំងស្រុងនូវអនុស្សរណៈយោគយល់លើកទី៥ ចំនួន ៤០ ម៉ឺនតោន ដែលបានបញ្ចប់ក្នុងខែតុលា ឆ្នាំ២០២១ និងបានធ្វើការចាប់ផ្តើមអនុវត្តន៍ការបញ្ជាទិញអង្ករតាមអនុស្សរណៈយោគយល់លើកទី៦ បានចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១។ គិតត្រឹមចុងខែកុម្ភៈ ឆ្នាំ២០២២ បរិមាណអង្ករចំនួន ១១៣ ០០០ តោន បានធ្វើការចុះកិច្ចសន្យាបញ្ជាទិញរួចរាល់ ហើយចំនួន ៨៦ ០០០តោន ក៏បានប្រគល់ជូនអ្នកបញ្ជាទិញរួចរាល់ផងដែរ។

សម្រាប់ខែមករា និង ខែកុម្ភៈ ឆ្នាំ២០២២ បរិមាណអង្ករចំនួន ៥២ ០៥៧ តោន ក្នុងចំណោមបរិមាណអង្ករសរុបដែលបាននាំចេញទៅប្រទេសចិន ត្រូវបានទិញតាមរយៈក្រុមហ៊ុនសាជីវកម្ម COFCO ដែលបរិមាណនេះមានកំណើនចំនួន ៥៦% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០២១។

នៅក្នុងកិច្ចប្រជុំនេះដែរ ភាគីពាក់ព័ន្ធ បានធ្វើការចែករំលែកព័ត៌មានអំពីការរីកចម្រើន ជាពិសេសការពេញនិយម និងចាប់ផ្តើមមានតម្រូវការខ្ពស់លើអង្ករក្រអូបប្រភេទសែនក្រអូប និងបានពិភាក្សាលើការប្រឈមមួយចំនួនដែលត្រូវដោះស្រាយរួមគ្នា ក្នុងគោលបំណងជំរុញឱ្យការអនុវត្តលើអនុស្សរណៈយោគយល់ចំនួន ៤០ម៉ឺនតោន ដែលបានចុះហត្ថលេខានៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ដែលបានសម្រេចតាមផែនការ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ Kampucheathmey ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។*

## តើវិស័យអចលនទ្រព្យកម្ពុជាអាចរងប៉ះពាល់ពីសង្គ្រាម រុស្ស៊ីនិងអ៊ុយក្រែនដែរឬទេ ?



*ដោយ ខេមបូណូមីស*

អ្នកជំនាញក្នុងវិស័យអចលនទ្រព្យនៅកម្ពុជាមើលឃើញថា សង្គ្រាមរវាងរុស្សី និងអ៊ុយក្រែន មិនបានជះឥទ្ធិពលធ្ងន់ធ្ងរដល់វិស័យអចលនទ្រព្យ និងការវិនិយោគនៅកម្ពុជានោះទេ។ ក៏ប៉ុន្តែប្រសិនបើសង្គ្រាមនេះវិវត្តក្លាយជាសង្គ្រាមរវាងរុស្ស៊ី និងអឺរ៉ុបប្រាកដណាស់ វានឹងជះឥទ្ធិពលមិនល្អមកលើវិស័យអចលនទ្រព្យ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជា ដែលកំពុងរងការគំរាមកំហែងពីវិបត្តិកូវីដ-១៩ប្រភេទអូមីក្រុងស្រាប់។ ប្រសិនបើសង្គ្រាមនេះបានវិវត្តកាន់តែធំនៅក្នុងតំបន់អឺរ៉ុប នោះចង់មិនចង់វានឹងគំរាមកំហែងដល់វិស័យនានា រួមទាំងសេដ្ឋកិច្ចទូទាំងពិភពលោកជាក់ជាមិនខាន។

ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន លី ហួរ រំពឹងថា សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែននឹងមិនវិវត្តរីកដុះដាលរហូតក្លាយជាសង្គ្រាមលោកនោះទេ។ វិបត្តិនៅអ៊ុយក្រែន វាលើសពីសមត្ថភាពដែលអ្នកវិនិយោគនៅកម្ពុជាត្រូវគិត ហើយអ្នកវិនិយោគក៏មិនគួរគិតពីបញ្ហាខ្លាំងពេកនោះដែរ។ ការអភិវឌ្ឍន៍នឹងមិនអាចរីកចម្រើន ឬដំណើរការទៅមុខបានឡើយ ប្រសិនបើអ្នកវិនិយោគរវល់តែផ្តោតការយកចិត្តទុកដាក់ខ្លាំងពេកលើវិបត្តិនៅអ៊ុយក្រែន។

នាយិកាគ្រប់គ្រងក្រុមហ៊ុនអចលនទ្រព្យ PropNex បានគូសបញ្ជាក់ថា ទោះបីវិបត្តិសង្គ្រាមរវាងរុស្ស៊ីជាមួយអ៊ុយក្រែនមិនបានជះឥទ្ធិពលដោយផ្ទាល់មកលើវិស័យអចលនទ្រព្យនៅកម្ពុជា តែវាបានធ្វើឱ្យប៉ះពាល់ដល់ផ្លូវអារម្មណ៍របស់អ្នកវិនិយោគ ដែលតាមដាន និងផ្តោតការយកចិត្តទុកដាក់លើបញ្ហានេះ។ មួយវិញទៀត វិបត្តិនៅអ៊ុយក្រែនបានជំរុញតម្លៃប្រេងឥន្ធនៈ និងសម្ភារផ្គត់ផ្គង់ឲ្យវិស័យសំណង់មួយចំនួនបានហក់ឡើងថ្លៃខ្ពស់ ដែលធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍វិស័យអចលនទ្រព្យ និងសំណង់នៅកម្ពុជា៕ *ដោយ ម៉ែន ខែមរៈ* *ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។*

## ក្រុមហ៊ុនសង់បុរី ឬផ្ទះល្វែងខ្លះថា ធ្វើផ្ទះឬវីឡា តែ១០០ ប៉ុន្តែជាក់ស្តែងធ្វើរហូតដល់១៥០ ទៅ២០០ផ្ទះ និងបង់ពន្ធមិនត្រឹមត្រូវ




*ដោយ sbm.news*

អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រកាសថា ដើម្បីឱ្យមានតម្លាភាពសម្រាប់អ្នកបង់ពន្ធ អគ្គនាយកដ្ឋានពន្ធដារ នឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងលេខកូដសម្គាល់អចលនទ្រព្យ។ ករណីក្រុមហ៊ុនសាងសង់បុរី ឬផ្ទះល្វែង មិនបង់ពន្ធ គឺមិនអាចកាត់ឈ្មោះផ្ទេរកម្មសិទ្ធិបានឡើយ។ ការប្រកាសរបស់មន្រ្តីជាន់ខ្ពស់ពន្ធដាររូបនេះ ធ្វើឡើងបន្ទាប់ពីអគ្គនាយកដ្ឋានពន្ធដារ រកឃើញថា ក្រុមហ៊ុនសង់បុរី ឬផ្ទះល្វែងមួយចំនួន ប្រកាសពន្ធថា ធ្វើផ្ទះឬវីឡាតែ១០០ទេ ក៏ប៉ុន្តែជាក់ស្តែង ធ្វើរហូត

ដល់១៥០ ទៅ២០០ផ្ទះ ដោយមិនបង់ពន្ធឱ្យបានត្រឹមត្រូវ។ ដូច្នេះ អគ្គនាយកដ្ឋានពន្ធដារ នឹងរៀបចំកម្មវិធី QR កូដ សម្រាប់គ្រងអចលនទ្រព្យទៅចេញជាប្រព័ន្ធ ដើម្បីឱ្យដឹងថា អ្នកនឹងមកទិញផ្ទះពីម្ចាស់បុរី ត្រូវមាន QR កូដ បើអ្នកណាទិញដោយគ្មាន QR កូដ មានន័យថា ម្ចាស់បុរីមិនបង់ពន្ធ និងមិនបានចុះបញ្ជីត្រឹមត្រូវ។

ប្រព័ន្ធគ្រប់គ្រងលេខកូដសម្គាល់អចលនទ្រព្យ អនុវត្តចំពោះក្រុមហ៊ុនសង់បុរី ឬផ្ទះល្វែងនេះ អាចដំណើរការនៅចុងខែមេសា ឬដើមខែឧសភា ឆ្នាំ២០២២ ខាងមុខនេះ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារ កំពុងអភិវឌ្ឍកម្មវិធីនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ sbm.news ចេញផ្សាយថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២។*

## ខេត្តព្រៃវែង និង តាកែវ ក្លាយជាខេត្តផលិតស្រូវប្រាំងលើសផែនការធំជាងគេរបស់កម្ពុជា



*ដោយ Kampucheathmey*

ពីមួយឆ្នាំទៅមួយឆ្នាំ ការធ្វើស្រែប្រាំងរបស់កសិករកម្ពុជាមានការកើនឡើងជាលំដាប់ ធ្វើឱ្យផ្ទៃដីដាំដុះស្រូវប្រាំងកើនឡើងជាមធ្យមពី ៣ ម៉ឺនហិកតា ទៅ ៥ ម៉ឺនហិកតា ក្នុង១ឆ្នាំ។ ខេត្តដែលផលិតស្រូវប្រាំងដ៏សំខាន់ ២ គឺខេត្តតាកែវ និងខេត្តព្រៃវែង អនុវត្តបានជាង ១០ ម៉ឺនហិកតា នៅក្នុងខេត្តនីមួយៗ។

រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយមបានឱ្យដឹងថា ការងារបង្កបង្កើនផលស្រូវប្រាំងលើផ្ទៃដីស្រូវវស្សាក្នុងរដូវប្រាំង ឆ្នាំ ២០២១-២០២២ មានកំណើនយ៉ាងគំហុក ពិសេសនៅក្នុងខេត្តព្រៃវែង បន្ទាប់ពីប្រព័ន្ធប្រឡាយវ៉ៃគោ ដែលបានទាញយកទឹកពីទន្លេមេគង្គដោយស្ថានីយបូមទឹក ប្រើថាម ពលអគ្គិសនីនៅរដូវប្រាំង បានធ្វើរួចជាមួយនឹងការធ្វើអនុត្តរភាពប្រព័ន្ធស្រោចស្រពនៅតាមមូលដ្ឋានរួចជាបន្តបន្ទាប់មក។នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ផ្ទៃដីបង្កបង្កើនផលស្រូវប្រាំងបានកើនជាមធ្យមក្នុងមួយឆ្នាំពី ៣ ម៉ឺនទៅ ៥ម៉ឺនហិកតាក្នុង១ឆ្នាំ។ តាមការព្យាករណ៍ ក្នុងរយៈពេលពី ៣ ទៅ ៥ឆ្នាំខាងមុខ ការដាំដុះស្រូវប្រាំងលើផ្ទៃដីស្រូវវស្សាអាចនឹងធ្វើបានដល់ ១ លានហិកតាក្នុងមួយឆ្នាំ បន្ទាប់ពីប្រព័ន្ធធារាសាស្ត្រធំៗ ជាមួយនឹងប្រព័ន្ធ ស្រោចស្រពត្រូវបានធ្វើពង្រីកបន្ថែមច្រើននៅតាមមូលដ្ឋាន។ ខេត្តជម្រុកស្រូវប្រាំងដ៏សំខាន់ដូចជាខេត្តតាកែវ និងខេត្តព្រៃវែង អនុវត្តបានជាង ១០ ម៉ឺនហិកតានៅក្នុងខេត្តនីមួយៗ។ ខេត្តតាកែវ អនុវត្តបាន ១០៨ ៨៩៥ ហិកតាស្មើនឹង ១៣៦,១២%។ ខេត្តព្រៃវែងអនុវត្តបាន ១១៨ ៥៨២ ហិកតាស្មើនឹង ១៥៨,១១%នៃផែនការ គិតត្រឹមដំណាច់ខែកុម្ភៈ។ ការដាំដុះស្រូវប្រាំងបានលើសផែនការប្រចាំឆ្នាំរបស់ខេត្តទាំងពីរនេះ កើតមានឡើងបន្ទាប់ពីប្រព័ន្ធធារាសាស្ត្រនៅក្នុងខេត្ត ត្រូវបានស្តារពង្រឹង និងពង្រីកបានច្រើនរួចជាបន្តបន្ទាប់។ សម្រាប់ខេត្តព្រៃវែងដែលមានកំណើនការដាំដុះស្រូវប្រាំងច្រើននៅលើផ្ទៃដីស្រូវវស្សានេះ អាចនឹងកើនឡើងច្រើនជាងនេះទៀត នៅពេលប្រព័ន្ធធារាសាស្ត្រត្រូវបានធ្វើអនុត្តរភាពបន្ថែមទៀតនៅតាមមូលដ្ឋាន ដោយបន្តពីប្រព័ន្ធមេនៃប្រព័ន្ធប្រឡាយវ៉ៃគោ។ ប្រព័ន្ធប្រឡាយវ៉ៃគោជាប្រព័ន្ធទាញយកទឹកពីទន្លេមេគង្គដោយស្ថានីយបូមទឹកប្រើថាមពលអគ្គិសនីនៅរដូវប្រាំង និងនៅក្នុងរដូវវស្សាបើកទ្វារទាញយកទឹកពេលទឹកទន្លេឡើងដល់កម្ពស់លើសពី ១០ ម៉ែត្រ នៅខេត្តកំពង់ចាម។ ក្រៅពីខេត្តតាកែវ និង ព្រៃវែង ការងារបង្ក

បង្កើនផលស្រូវប្រាំងឆ្នាំ ២០២១-២០២២ មានខេត្តជាច្រើនទៀតអនុវត្តបានលើសផែនការដូចជា ខេត្តកំពត បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង ប៉ៃលិន កំពង់ធំ ជាដើម។

យោងតាមតាមរបាយការណ៍បង្កបង្កើនផលស្រូវប្រាំងឆ្នាំ ២០២១-២០២២ គិតត្រឹមដំណាច់ខែកុម្ភៈនៅទូទាំងប្រទេសអនុវត្តបាន ៦៣៥ ៩៩៥ ហិកតា ស្មើនឹង ១៣៦,៨៨%។ ចំណែកការងារបង្កបង្កើនផលស្រូវប្រាំងឆ្នាំ ២០២១-២០២២ ក្នុងរយៈពេលដូចគ្នានៅទូទាំងប្រទេស អនុវត្តបាន ៦២៤ ៦៨០ ហិកតា ស្មើនឹង ១៣៧,៧៦%៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ Kampucheathmey ចេញផ្សាយថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២។*

## ស្ថាប័នរដ្ឋ និងឯកជនជាង១០ហើយ បានទិញបណ្ណបំណុលក្រុមហ៊ុនអភិវឌ្ឍព្រលានយន្តហោះភ្នំពេញថ្មី




*ដោយ ខេមបូណ្ឌមីស(ព្រលានយន្តហោះអន្តរជាតិភ្នំពេញ)*

ក្រោយការស្នើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា យើងសង្កេតឃើញមានគ្រឹះស្ថានហិរញ្ញវត្ថុឯកជន និងស្ថាប័នរដ្ឋជាច្រើន បានចូលរួមទិញមូលបត្របំណុលមានអ្នកធានារបស់ក្រុមហ៊ុនសាងសង់អាកាសយានដ្ឋានអន្តរជាតិតេជោ ឬព្រលានយន្តហោះអន្តរជាតិភ្នំពេញថ្មី នៅខេត្តកណ្ដាលជាបន្តបន្ទាប់។ ជាក់ស្ដែង គិតតាំងពីក្រុមហ៊ុន CAIC ដែលជាអ្នកអភិវឌ្ឍន៍គម្រោងអាកាសយានដ្ឋាននេះ បានបោះផ្សាយលក់មូលបត្របំណុលមកទល់បច្ចុប្បន្ន មានស្ថាប័នហិរញ្ញវត្ថុឯកជន និងស្ថាប័នរដ្ឋជាង១០ហើយ បានចូលរួមវិនិយោគ ទិញបំណុលនេះ និងប្រមូលបានទុនសរុបជាង១៥០លានដុល្លារអាមេរិក។ ក្រុមហ៊ុន ដែលចូលរួមទិញមូលបត្របំណុលទាំងនេះ ទទួលបានអត្រាការប្រាក់ ៥,៥% ក្នុងមួយឆ្នាំសម្រាប់រយៈពេលបីឆ្នាំ។

អគ្គនាយកក្រុមហ៊ុន OCIC ដែលជាក្រុមហ៊ុនមេរបស់ក្រុមហ៊ុន CAIC បានអះអាងថា ក្រុមហ៊ុន CAIC គ្រោងបោះផ្សាយលក់មូលបត្របំណុលប្រមាណ៣០០លានដុល្លារអាមេរិក។ គោលបំណងនៃការបោះផ្សាយលក់នេះ គឺដើម្បីកៀរគរទុនសម្រាប់ទ្រទ្រង់ដំណើរការសាងសង់ និងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី ដែលបច្ចុប្បន្នសម្រេចការសាងសង់បានជាង៣០% ដោយគ្រោងបញ្ចប់ការសាងសង់ដំណាក់កាលទី១នៅអំឡុងឆ្នាំ២០២៣ ខាងមុខ។ ការចូលរួមទិញសញ្ញាបណ្ណនេះ គឺជាការចូលដល់ការអភិវឌ្ឍន៍ព្រលានយន្តហោះថ្មី ដែលកាត់បន្ថយការប្រើប្រាស់ទុនពីក្រៅប្រទេស ហើយការគ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះ ក៏ទទួលបានផលចំណេញពីអត្រាការប្រាក់។ គ្រឹះស្ថានហិរញ្ញវត្ថុឯកជន និងស្ថាប័នរដ្ឋដែលបានទិញមូលបត្របំណុលមានអ្នកធានារបស់ CAIC មានដូចជាធនាគារអេស៊ីលីដា, ហត្ថា, ជីបម៉ុង, ព្រីនស៍, ប្រៃសណីយ៍កម្ពុជា, ធនាគារវីង, អាល់ហ្វា, ABA, FTB, APD, ក្រុមហ៊ុនធានារ៉ាប់រងប្រូដិនសល់, AIA, សាជីវកម្មធានាឥណទានកម្ពុជា និងបេឡាជាតិសន្តិសុខសង្គមជាដើម៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។*

## ការនាំចេញអង្ករបស់ប្រទេសកម្ពុជាទៅកាន់រុស្ស៊ី និងអ៊ុយក្រែន ពុំទទួលរងផលប៉ះពាល់ឡើយបើទោះបីជាប្រទេសទាំងពីរកំពុងមានស្ថានភាពតានតឹងក៏ដោយ



*ប្រភព៖ភ្នំពេញប៉ុស្តិ៍, 2021 រូបភាព៖ ហុង មិនា*

យោងតាមលោក សុង សារ៉ន ប្រធានកសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) បានបង្ហាញថា ការនាំចេញអង្ករទៅកាន់ប្រទេសរុស្ស៊ី ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះគឺមានចំនួន ១៧ ៥១២តោន។ ក្នុងនោះសម្រាប់ឆ្នាំ ២០២១ ការនាំចេញមានចំនួន ២ ២២៣តោន សមមាត្រនឹង ១,៩លានដុល្លារ។ ចំណែកក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ ២០២២ បរិមាណអង្ករនាំចេញទៅប្រទេសរុស្ស៊ីមានចំនួន ២០០ តោនដែលស្មើនឹងទឹកប្រាក់ ២០០ ៦៤០ ដុល្លារ។

ស្របពេលជាមួយគ្នានេះដែរ សម្រាប់ការនាំអង្ករចេញទៅកាន់ប្រទេសអ៊ុយក្រែន ពីឆ្នាំ ២០១៧-២០២១ គឺមានបរិមាណត្រឹមតែ ៥៧២ តោនប៉ុណ្ណោះ។ ដូចនេះ ទីផ្សារនាំចេញអង្ករកម្ពុជាទៅកាន់ប្រទេសអ៊ុយក្រែន និងប្រទេសរុស្ស៊ីមិនទទួលរងផលប៉ះពាល់ពីវិបត្តិនៃការប្រយុទ្ធគ្នារវាងប្រទេសទាំងពីរឡើយ ដោយសារតែបរិមាណនាំចេញមានកម្រិតទាប ម្យ៉ាងវិញទៀតប្រទេសទាំងពីរមិនមែនជាទីផ្សារធំសម្រាប់ការនាំចេញអង្ករកម្ពុជាឡើយ នឹងមិនជះឥទ្ធិពលអវិជ្ជមាន សម្រាប់ការនាំចេញអង្កររបស់កម្ពុជានោះឡើយ។

ដោយឡែក ក្នុងឆ្នាំ២០២២ អ្វីដែលចោទជាបញ្ហាគឺកត្តាកង្វះទូកុងតឺន័រផ្ទុកអង្ករ និងការកើនឡើងនៃតម្លៃដឹកជញ្ជូនផ្លូវសមុទ្រជាពិសេសទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប។ ដូចនេះ CRF បានធ្វើពិពិធកម្មទីផ្សារជាបន្ទាប់ ពិសេសការផ្តោតលើការជំរុញទៅកាន់ទីផ្សារប្រទេសចិន និងប្រទេសនៅក្នុងតំបន់អាស៊ាន។

របាយការណ៍ក្រសួងកសិកម្មបានបង្ហាញថា ក្នុងរយៈពេលពីរខែដើមឆ្នាំ២០២២ កម្ពុជានាំចេញអង្ករទៅទីផ្សារអន្តរជាតិសរុបចំនួន ១០៣ ០៥៨ តោន កើនឡើង ៣៥,២% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ។ ក្នុងនោះការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុបមានបរិមាណសរុប ២៦ ៥០៧ តោន កើនឡើង ៣៩,៥% , ប្រទេសចិន មានចំនួន ៥៦ ៣៨៥ តោន កើនឡើងជិត ៥០%, តំបន់អាស៊ាន (៣ ប្រទេស) មានបរិមាណ ៩ ៣៧០ តោន កើនឡើង ៥០,៤% និងទិសដៅដទៃទៀត (១៦ ប្រទេស) មានបរិមាណ ១០ ៧៩៦ តោន ថយចុះ -១៩%។

កាលពីឆ្នាំ ២០២១ កម្ពុជានាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ បានចំនួនជាង ៦១៧ ០៦៩ តោន បានធ្លាក់ចុះ ១០,៦%បើធៀបនឹងឆ្នាំ ២០២០។ ចំណែកការនាំចេញស្រូវមានចំនួន ៣, ៥លានតោន កើនឡើង ៦១%៕

*ដោយ សេន ចន្ទ*

*ប្រភព៖ postkhmers,ចេញផ្សាយថ្ងៃទី០៧ខែមិនា ឆ្នាំ២០២២*

## លំហូរចូលFDI កម្ពុជាកើន២២% ត្រឹម ៤,៣៥៣ពាន់ដុល្លារក្នុងឆ្នាំ២០២១




*ប្រភព៖ ខ្មែរថាម , រូបភាព៖ស៊ីវ ចាន់ណា*

យោងតាមឯកឧត្តម សុខ ចិន្តាសោភា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានឱ្យដឹងថា៖

កម្ពុជាបានចាប់យកការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) មានចំនួន ៤,៣៥ ពាន់លានដុល្លារក្នុងឆ្នាំ ២០២១ កើនឡើង ២២% ធៀបនឹងឆ្នាំមុន ដោយមានប្រទេសចិន សហរដ្ឋអាមេរិក និងសិង្ហបុរី ដែលជាអ្នករួមចំណែកធំបំផុតនៅក្នុងការវិនិយោគនេះ។

កាលពីនៅថ្ងៃទី ២២ ខែធ្នូឆ្នាំ ២០២១កន្លងទៅនេះ រដ្ឋាភិបាលបានដាក់ចេញនូវឯកសារសំខាន់មួយនៃក្របខណ្ឌនៃផែនការស្តារសេដ្ឋកិច្ចកម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ សម្រាប់ឆ្នាំ ២០២១-២០២៣ រួមមាន យុទ្ធសាស្ត្រនៃការស្តារឡើងវិញ (Recovery) ការកែទម្រង់ (Reform) និងការកសាងភាពធន់ (Resilience)»។

ក្របខណ្ឌទាំងនេះមានទំនាក់ទំនងនឹងការពង្រីកសេដ្ឋកិច្ច ការកែទម្រង់ ពិពិធកម្មសេដ្ឋកិច្ច ការសម្របសម្រួលពាណិជ្ជកម្ម ច្បាប់នានាស្តីពីតំបន់សេដ្ឋកិច្ចពិសេស និងការអនុវត្តច្បាប់វិនិយោគថ្មីសម្រាប់ទាក់ទាញកាចាប់អារម្មណ៍អ្នកវិនោយោគទាំងក្នុងតំបន់ និងសកលលោក ដើម្បីបង្កើនរបារបន្ថែមទៀត និងបង្កើនបរិយាកាលអំណោយផលសម្រាប់ អ្នកវិនិយោគនៅកម្ពុជា។

បន្ថែមពីនេះ រដ្ឋាភិបាលបានជំរុញការវិនិយោគរួមមាន៖ កម្មសិទ្ធបរទេស ១០០%នៃក្រុមហ៊ុន ថ្ងៃឈប់សម្រាកពន្ធសាជីវកម្មរហូតដល់ប្រាំបួនឆ្នាំ( តាមពីក្រោយដោយការវិលត្រឡប់ទៅពន្ធសាជីវកម្មដែលត្រូវបង់អតិបរមា ២០ %) ការកាត់តម្លៃ ១៥០ % លើធនធានមនុស្ស និងការទិញសុខុមាលភាពបុគ្គលិក ទំនិញអនុគ្រោះពន្ធ និងគ្មានការរឹតបន្តឹងលើការធ្វើមាតុភូមិនិវត្តន៍ដើមទុន។ ក្រៅពីនេះ រដ្ឋាភិបាលជាពិសេសធនាគារកណ្តាលកំពុងខិតខំលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណជាតិ( ប្រាក់រៀល )ជាងប្រាក់ដុល្លារ ព្រោះការប្រែប្រួលអត្រាប្តូរប្រាក់ប៉ះពាក់យ៉ាងធ្ងន់ធ្ងរដល់ការចំណាយផលិតកម្មរយៈពេលវែង៕*ដោយ មុំ ចិន្តា*

*ប្រភព៖ ខ្មែរថាម ចេញផ្សាយថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២*

## រោងចក្រផលិតដែកដំបូងគេនៅខេត្តបន្ទាយមានជ័យ បើដំណើរការជាផ្លូវការ



*ដោយ Kampucheathmey*

ខេត្តបន្ទាយមានជ័យ បានដាក់ឱ្យដំណើរការរោងចក្រផលិតដែកសម្រាប់គ្រឿងសំណង់ជាលើកដំបូង ដែលជាការវិនិយោគចម្រុះខ្មែរ ចិន និងថៃ ដែលស្ថិតនៅផ្លូវជាតិលេខ៥៩ ភូមិខ្លាងាប់ ឃុំទួលពង្រ ស្រុកម៉ាឡៃ។

តំណាងឱ្យក្រុមហ៊ុន ប៉ាង ណាគ្រីរៀលអ៊ីសស្ទេត ឯ.ក បានឱ្យដឹងថា ការបើករោងចក្រផលិតដែកទី១ នៅខេត្តបន្ទាយមានជ័យនេះ គឺដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចនៅមូលដ្ឋាន ពិសេសចង់ប្រែក្លាយតំបន់អតីតព្រៃដាច់ស្រយាល តំបន់អតីតសមរភូមិសង្គ្រាម និងតំបន់ចម្ការមីន គ្រាប់យុទ្ធភណ្ឌក្លាយទៅជាតំបន់អភិវឌ្ឍន៍។ កន្លងមក និងចំពោះមុខ ក្រុមហ៊ុន បាននឹងកំពុងអភិវឌ្ឍន៍តំបន់នេះលើគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជាច្រើនខ្សែ ដោយចំណាយថវិកាប្រមាណ ៣លានដុល្លារអាមេរិក ដោយវិនិយោគលើវិស័យអចលនវត្ថុ, បង្កើតផ្សារ, រោងចក្រ, សេវាកម្ម មួយចំនួន ដែលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងគម្រោងបន្ត គឺក្រុមហ៊ុននឹងកសាងរោងចក្រផលិតសំបករថយន្តនិងអាជីវកម្មវិស័យផ្សេងទៀតដើម្បីផ្តល់ឱកាសការងារជូនពលរដ្ឋក្នុងមូល

ដ្ឋានដើម្បីលើកកម្ពស់ជីវិភាពរស់នៅរបស់ពួកគាត់ឱ្យកាន់តែប្រសើរឡើង។

អភិបាលខេត្តបន្ទាយមានជ័យ បានស្នើអោយក្រុមហ៊ុន និងម្ចាស់អាជីវកម្ម សូមផ្តល់អាទិភាពកម្លាំងពលកម្ម ជូនពលរដ្ឋនៅឃុំទួលពង្រស្រុកម៉ាឡៃខេត្តបន្ទាយមានជ័យ។ លោកអភិបាលខេត្ត បានប្តេជ្ញានឹងបន្តសម្របសម្រួល បង្កលក្ខណ:ងាយស្រួល ជូនវិនិយោគិនខ្មែរ និងបរទេស ដែលមកបណ្តាក់ទុនរកស៊ីនៅក្នុងខេត្តបន្ទាយមានជ័យផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖Kampucheathmeyចេញផ្សាយថ្ងៃទី៩ខែមីនាឆ្នាំ២០២២។*

## ក្រុមអ្នកចិញ្ចឹមត្រីថា ចំណីឡើងថ្លៃកាន់តែខ្ពស់ជាបន្តបន្ទាប់ ខណៈតម្លៃទីផ្សារត្រីនៅតែមានទាប



*ដោយ ខេមបូណ្ឌមីស(រូបតំណាង៖ ការចិញ្ចឹមត្រីនៅកម្ពុជា )*

ប្រជាពលរដ្ឋប្រកបរបរចិញ្ចឹមត្រីកំពុងប្រឈមនឹងបញ្ហាកាន់តែខ្លាំងឡើង។ ប្រធានសមាគមវារីវប្បករកម្ពុជា បានបញ្ជាក់ប្រាប់ថា ប្រជាពលរដ្ឋដែលប្រកបរបចិញ្ចឹមត្រីនៅពេលបច្ចុប្បន្នមានការថយចុះជាងមុន

ដោយសារតែការចំណាយថ្លៃដើមពិសេសចំណីត្រីកើនឡើងកាន់តែខ្ពស់ ហើយត្រីក៏មិនសូវមានទីផ្សារ និងតម្លៃទាប ពុំសូវទទួលបានផលចំណេញច្រើន និងអាចនឹងឈានដល់ការខាតផងដែរ។ ម្យ៉ាងវិញទៀត ការនាំចូលត្រីច្រើនពីប្រទេសក្រៅផង ក៏បានធ្វើឱ្យអ្នកចិញ្ចឹមត្រីក្នុងស្រុកជួបបញ្ហាប្រឈមកាន់តែខ្លាំងផងដែរ។

អ្នកប្រកបរបរចិញ្ចឹមត្រីប្រា នៅឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល បានបញ្ជាក់ដែរថា ចំណាយលើចំណីត្រី និងវត្ថុធាតុដើមថ្លៃ ហើយទិន្នផលលក់ចេញមានតម្លៃទាប មិនសមាមាត្រគ្នានឹងការចំណាយថ្លៃដើម។ កាលពីមុនចំណីត្រី( កន្ទួក )តម្លៃត្រឹមតែជាង៩០០ រៀលក្នុងមួយគីឡូក្រាមប៉ុណ្ណោះ តែបច្ចុប្បន្នឡើងរហូតដល់ជាង ១ ៣០០រៀលក្នុងមួយគីឡូក្រាម។ ក្រៅពីកន្ទួកលោកក៏ប្រើប្រាស់ត្រីនុយ ឬកូនត្រីល្អិតៗតូចៗ សម្រាប់ធ្វើជាចំណីត្រីផងដែរ ដែលមានតម្លៃរហូតដល់ ១ ៣០០រៀលក្នុងមួយគីឡូក្រាម។ ស្របពេលចំណីត្រីឡើងថ្លៃ បច្ចុប្បន្នត្រីប្រារបស់លោកអាចលក់បានក្នុងតម្លៃ ៤៥០០រៀលក្នុងមួយគីឡូក្រាមប៉ុណ្ណោះ។

អ្នកប្រកបរបរចិញ្ចឹមត្រី នៅសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ បានឱ្យដឹងដែរថា ក្នុងឆ្នាំ ២០២២ នេះ ចំណីត្រីបន្តឡើងថ្លៃកាន់តែខ្ពស់ ដែលជាបញ្ហាដល់ការចិញ្ចឹមត្រី។ បច្ចុប្បន្នត្រីលក់បានក្នុងតម្លៃ ៤៧០០ រៀលក្នុងមួយគីឡូក្រាម ចំពោះត្រីប្រា និង ៦៨០០ រៀលក្នុងមួយគីឡូក្រាមចំពោះត្រីពោរ។

កន្លងមកខាងភាគីចិនបានមកសិក្សាអំពីនីតិវិធីក្នុងការនាំចេញត្រីប្រាពីកម្ពុជាទៅប្រទេសចិន ហើយអ្នកចិញ្ចឹមត្រីទាំងអស់បានបំពេញលក្ខខ័ណ្ឌ ការអនុវត្តន៍កសិកម្មល្អ (GAP) ទៅកាន់ភាគីប្រទេសចិនរួចរាល់ហើយ ខណៈដែលពេលនេះភាគីប្រទេសចិនកំពុងបន្តដំណើរការចចាជាមួយក្រសួងកសិកម្ម។ ប្រធានសមាគមវារីវប្បករកម្ពុជា សង្ឃឹមថា ខាងភាគីចិន និងក្រសួងកសិកម្មកម្ពុជា នឹងពន្លឿនការងារនាំចេញត្រីប្រានេះឱ្យបានឆាប់ ដើម្បីជួយបង្កើនទីផ្សារត្រីកម្ពុជាដែលកំពុងជួបការលំបាក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិកលើមុខទំនិញនៅក្នុងខែធ្នូ ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែធ្នូ ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុបចំនួន ៧៦២,៧លានដុល្លារ ធ្លាក់ចុះប្រមាណជា ៧,៦% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុប ៧២៧,១លានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០២១ ធ្លាក់ចុះប្រមាណជា ៨,៤% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២១។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញរួមមាន៖កាបូបយួរ កាបូបលុយ សំលៀកបំពាក់ និងផលិតផលផ្សេងៗទៀត។

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** | **534.9** | **693.9** | **965.1** | **980.2** | **1091.3** | **825.7** | **762.7** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% | -17.8% | 29.7% | 39.1% | 1.6% | 11.3% | -24.3% | -7.6% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 | 28.8 | 33.2 | 43.0 | 24.8 | 43.1 | 31.5 | 35.6 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% | -24.4% | 15.3% | 29.5% | -42.3% | 73.8% | -26.9% | 13.0% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 | 506.1 | 660.7 | 922.1 | 955.4 | 1048.2 | 794.2 | 727.1 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% | -17.3% | 30.5% | 39.6% | 3.6% | 9.7% | -24.2% | -8.4% |

ក៏ប៉ុន្តែ ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់សរុប ៣៥,៦លានដុល្លារនៅក្នុងខែធ្នូ ឆ្នាំ២០២១ កើនឡើងប្រមាណជា១៣% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២១។ ការនាំចូលទំនិញសំខាន់ៗទាំងនេះ រួមមាន៖ រថយន្តធ្វើដំណើរ គ្រឿងបន្លាស់រថយន្ត ប្លាស្ទា វ៉ាក់សាំង ឈាម នំសណ្តែកសៀង និងផលិតផលផ្សេងៗទៀត៕*ដោយ មិត្ត ចន្ទី*

ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យណិជ្ជកម្មសហរដ្ឋអាមេរិក

(គិតជាលានដុល្លារ)

## តារាងទី២៖ ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែវិច្ឆិកា ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ បានចំណាយលើអត្ថប្រយោជន៍សង្គម ក្នុងទំហំទឹកប្រាក់សរុបចំនួន ២៥៥ប៊ីលានរៀល ដែលមានការធ្លាក់ចុះប្រមាណជា ៣៧,១% បើធៀបនឹងខែតុលានៃឆ្នាំ២០២១។

ជាក់ស្តែង ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន ៤៣,៥១ប៊ីលានរៀល នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ៥៦,៣% បើធៀបនឹងខែតុលា ឆ្នាំ២០២១។

ទន្ទឹមនឹងនោះដែរ ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន២០២,១៦ប៊ីលានរៀល នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ មានការធ្លាក់ចុះប្រមាណជា ៣១,៥៨% បើធៀបនឹងខែតុលា ឆ្នាំ២០២១។

ក៏ប៉ុន្តែ ការចំណាយលើអំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ មានទំហំទឹកប្រាក់៩,៣៣ប៊ីលានរៀល នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ កើនឡើងប្រមាណជា ៧៥,៧១% បើធៀបនឹងខែតុលា ឆ្នាំ២០២១។ ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មិនមានទេ នៅក្នុងខែវិច្ឆិកាឆ្នាំ២០២១ នេះ៕ ដោយ មិត្ត ចន្ទី

| ការចំណាយឆ្នាំ២០២១(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| **អត្ថប្រយោជន៍សង្គម** | **103.40** | **114.72** | **240.59** | **115.28** | **376.94** | **365.53** | **479.33** | **364.04** | **443.06** | **405.64** | **255.00** |
| **កំណើន/ថយ(%)** | | 10.9% | 109.7% | -52.1% | 227.0% | -3.0% | 31.1% | -24.1% | 21.7% | -8.4% | -37.1% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 90.63 | 101.04 | 158.63 | 39.06 | 92.81 | 99.99 | 99.76 | 94.59 | 104.7 | 99.65 | 43.51 |
| **កំណើន/ថយ(%)** | | 11.5% | 57.0% | -75.4% | 137.6% | 7.7% | -0.2% | -5.2% | 10.7% | -4.8% | -56.3% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 9.54 | 8.85 | 75.32 | 65.65 | 266.78 | 255.92 | 370.71 | 257.70 | 330.36 | 295.45 | 202.16 |
| **កំណើន/ថយ(%)** | | -7.2% | 751.1% | -12.8% | 306.4% | -4.1% | 44.9% | -30.5% | 28.2% | -10.57% | -31.58% |
| អំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ | 3.23 | 4.83 | 6.64 | 10.57 | 11.73 | 9.62 | 8.86 | 8.94 | 8.00 | 5.31 | 9.33 |
| **កំណើន/ថយ(%)** | | 49.5% | 37.5% | 59.2% | 11.0% | -18.0% | -7.9% | 0.9% | -10.5% | -33.63% | 75.71% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | - | - | 5.62 | - | | 2.81 | - | 5.23 | - |

ប្រភព៖ តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ខែវិច្ឆិកាឆ្នាំ២០២១

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### សហព័ន្ធឧស្សាហកម្មថៃទាមទារឱ្យរាជរដ្ឋាភិបាលថៃដោះស្រាយលើបញ្ហាខ្វះខាតកម្លាំងពលកម្ម



*ប្រភព៖ Khmer Times រូបភាព៖ Apichart Jinakul*

លោក Suchart Chantaranakaracha អនុប្រធានសម្រាប់កម្លាំងពលកម្ម នៃសហព័ន្ធឧស្សាហកម្មថៃ បាននិយាយថា នៅខែមុននេះ សហព័ន្ធបានអំពាវនាវឱ្យរាជរដ្ឋាភិបាលថៃ បង្កើនល្បឿនក្នុងការចុះអនុស្សារណៈយោគយល់លើការនាំចូលកម្លាំងជាមួយប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ សហព័ន្ធឧស្សាហកម្មថៃ បានទាមទារការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាខ្វះខាតកម្លាំងពលកម្មធ្ងន់ធ្ងរនេះ ដោយសារបញ្ហានេះ នឹងអាចគំរាមកំហែងដល់ការងើបឡើងនៃសេដ្ឋកិច្ចថៃ។ ជាក់ស្តែង ថៃមានការខ្វះខាតកម្លាំងពលកម្មសរុប រហូតដល់ទៅ ៧០០ ០០០នាក់។

បន្ថែមពីនេះ សហព័ន្ធ ក៏បានលើកជាយោបល់ថា រដ្ឋមន្ត្រីពលកម្មថៃ គួរតែធ្វើការពិភាក្សាដោយផ្ទាល់ជាមួយនឹងរដ្ឋមន្ត្រីពលកម្មនៃប្រទេសទាំងបីនោះ ដើម្បីបង្កើនល្បឿនដំណើរការចុះអនុស្សារណៈយោគយល់នេះ។ រីឯ លោក Suchart បានបន្ថែមថា រាជរដ្ឋាភិបាល ក៏គួរកាត់បន្ថយលើចំណាយ និងគោលនយោបាយមិនចាំបាច់ ដើម្បីជួយសម្រួលដល់ដំណើរការនាំចូលពលកម្ម ហើយលោកក៏ស្នើឱ្យរាជរដ្ឋាភិបាលពិចារណាលើការផ្តល់ការលើកលែងទោសដល់ពលករខុសច្បាប់ និងដល់និយោជកដែលបំពានច្បាប់ពលកម្ម។

គួរបញ្ជាក់ថា ប្រទេសថៃ មានពលករសរុប ច្រើនជាង ២លាននាក់ ក៏ប៉ុន្តែ ពលករប្រមាណជា ៥០០ ០០០ ទៅ ៦០០ ០០០នាក់ បានត្រលប់ទៅមាតុប្រទេសវិញ បន្ទាប់ពីបាត់បង់ការងារ ក្នុងកំឡុងវិបត្តិជំងឺរាតត្បាតកូវីដ-១៩។ ហើយភាគច្រើននៃពលករទាំងនោះ មិនទាន់វិលត្រលប់ទៅធ្វើការនៅប្រទេសថៃនៅឡើយទេ៕

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ Khmer Times ចេញផ្សាយ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២*

### ទុនបម្រុងអន្តរជាតិហ្វីលីពីន មានលើសពីគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាអស្ថិរភាពទីផ្សារនានា




*ប្រភព៖ TheStar រូបភាព៖ Bloomberg*

ទេសាភិបាលធនាគារជាតិហ្វីលីពីន លោក Benjamin Diokno បានលើកឡើងថា ទោះបីជា រូបិយវត្ថុ(លុយ) ហ្វីលីពីនទទួលរងផលប៉ះពាល់ ដោយសារតែជម្លោះរុស្ស៊ី-អ៊ុយក្រែន ក៏ប៉ុន្តែ ទុនបម្រុងអន្តរជាតិរបស់ហ្វីលី-

ពីន គឺមានលើសពីគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហានានានៅលើទីផ្សារ។ ទន្ទឹមនេះដែរ ធនាគារកណ្តាលក៏មានឧបករណ៍លើកកម្ពស់សន្ទនីយភាព ក្នុងករណីដែលស្ថានភាពក្នុងស្រុកមានភាពតានតឹង ឬចលាចល។ គួរឱ្យកត់សម្គាល់ថា ចរាចរប្រាក់ប៉េសូ គឺត្រូវបានជួញដូរក្នុងស្ថានភាពចង្អៀត និងធ្លាក់ថ្លៃបន្តិចបន្តួច ដោយសារផលប៉ះពាល់ភូមិសាស្ត្រនយោបាយទៅលើតម្លៃប្រេង ដែលបណ្តាលមកពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន។ ទេសាភិបាលបានគូសសម្គាល់ថា ក្នុងសេណារីយ៉ូអាក្រក់បំផុត នោះតម្លៃប្រេងនឹងកើនដល់ ១២០-១៤០ដុល្លារក្នុង១បារ៉ែល។ រីឯ អតិផរណាជាមធ្យម នឹងមានអត្រា ៤,៤% ទៅ ៤,៧% ដែលលើសអតិផរណាគោលរបស់ធនាគារកណ្តាល (២%-៤%)៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ TheStar ចេញផ្សាយ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២*

## តុល្យភាពពាណិជ្ជកម្មរបស់ចិនក្នុងរយៈពេលពីរខែដំបូងឆ្នាំ២០២២

យោងតាមស្ថិតិគយបានបង្ហាញថា ក្នុងរយៈពេលពីរខែដំបូង(មករា-កុម្ភៈ)ឆ្នាំ២០២២ តម្លៃនៃការនាំចូលនឹងការនាំចេញរបស់ចិនសរុបមានចំនួន ៦ ២០០ ប៊ីលានយន់ កើនឡើង ១៣,៣% ធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំកន្លងទៅ។ ក្នុងនោះការនាំចេញមានចំនួន ៣ ៤៧០ ប៊ីលានយន់ កើនឡើង ១៣,៦% និងការនាំចូលមានចំនួន ២ ៧៣០ប៊ីលានយន់ កើនឡើង ១២,៩% ។ អតិរេកពាណិជ្ជកម្មមានចំនួន ៧៤០ប៊ីលានយន់ កើនឡើង ១៦,៣%។

សម្រាប់មុខទំនិញដែលប្រទេសចិនបាននាំចេញក្នុងរយៈពេលពីរខែដំបូងឆ្នាំ២០២២នេះរួមមាន៖ ផលិតផលមេកានិច និងអគ្គសនី(mechanical and electrical products)មានចំនួន ២,០២ទ្រីលានយន់ កើនឡើង ៩,៩% ស្មើនឹង៥៨,៣%នៃតម្លៃនាំចេញសរុប ក្នុងនោះរួមមាន (ឧបករណ៍ដំណើរការបញ្ជូនទិន្នន័យស្វ័យប្រវត្តិ (Automatic data processing)២៥០,៧៦ប៊ីលានយន់ ទូរស័ព្ទចល័តមានចំនួន ១៤៧,៨៧ប៊ីលានយន់ និងគ្រឿងប្រើប្រាស់ក្នុងផ្ទះមានចំនួន ៨៩,៧ប៊ីលានយន់)។ ចំណែកផលិតផលដែលប្រើប្រាស់កម្លាំងពលកម្មច្រើន(Labor-intensive products)មានចំនួន ៦២១,៤៦ប៊ីលានយន់ កើនឡើង៨,៩% ស្មើនឹង ១៧,៩%នៃតម្លៃនាំចេញសរុប ក្នុងចំណោមនោះរួមមាន (សម្លៀកបំពាក់ និងគ្រឿងផលិតសម្លៀកបំពាក់មានចំនួន ១៦២,២៧ប៊ីលានយន់ វាយនភណ្ឌ ១៥៧,៧ប៊ីលានយន់ ផលិតផលផ្លាស់ស្ទិកចំនួន ១០១,៩៥ប៊ីលានយន់ និងផលិតផលកសិកម្មមានចំនួន ៩១,១២ប៊ីលានយន់) ។ បន្ថែមពីនេះក៏មានការនាំចេញដែកថែបចំនួន ៨,២៣៤តោន និងប្រេងចម្រាញ់បាន៧,២៩៥លានតោនផងដែរ។

ចំណែកឯមុខទំនិញនាំចូលវិញរួមមាន រ៉ែដែកចំនួន ១៨១លានតោន ដែលបរិមាណនេះដូចទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ ហើយតម្លៃជាមធ្យមសម្រាប់នាំចូលបានធ្លាក់ចុះ ៣៦% និងមុខទំនិញមួយចំនួនទៀតដូចជា ប្រេងឆៅ ធ្យូងថ្ម ឧស្ម័នធម្មជាតិ សណ្តែងសៀង និងទំនិញមួយចំនួនផ្សេងទៀតការនាំចូលបានធ្លាក់ចុះនៅក្នុងរយៈពេលពីរខែដំបូងឆ្នាំ២០២២ នេះធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំកន្លងទៅ ការធ្លាក់ចុះនៃការនាំចូលនេះបណ្តាលមកពីតម្លៃជាមធ្យមសម្រាប់នាំចូលមានការកើនឡើង។

នៅក្នុរយៈពេលពីរខែដំបូងនេះការនាំចូល និងការនាំចេញសរុបទៅកាន់ដៃគូពាណិជ្ជកម្មធំៗរបស់ចិនរួមមាន ៖ សហគមន៍អឺរ៉ុប អាស៊ាន សហរដ្ឋអាមេរិក កូរ៉េខាងត្បូង និងប្រទេសតាមបណ្តោយ“ផ្លូវ ខ្សែក្រវ៉ាត់(Belt and Road)” មានកំណើន ១២,៤% ,១០,៥%,

៩,៧%,១៤,៩% និង ១៨,៣% រៀងគ្នាធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំកន្លងទៅ។*ដោយ មុំ ចិន្តា*

*ប្រភព៖ General Administration of Customs P.R. China*

| បរិយាយ | តម្លៃ(ប៊ីលានយន់) |
|---|---|
| ការនាំចេញ | 34,700 |
| ការនាំចូល | 27,300 |
| តុល្យភាពពាណិជ្ជកម្ម | 7,400 |

## ការនាំចេញវៀតណាមទៅរុស្ស៊ីចាប់ផ្ដើមរងប៉ះពាល់ដោយសារតែទណ្ឌកម្មលោកខាងលិច




*ដោយ ខេមបូណ្ឌមីស(ផែដឹកទំនិញរបស់វៀតណាម)*

ការដាក់ទណ្ឌកម្មពីសំណាក់ប្រទេសលោកខាងលិចទៅលើរុស្ស៊ី ជុំវិញវិបត្តិសង្គ្រាមនៅអ៊ុយក្រែន កំពុងរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់សកលលោក រួមទាំងប្រទេសដែលមានទំនាក់ទំនងពាណិជ្ជកម្មជាមួយរុស្ស៊ីផងដែរ។ អគ្គនាយកក្រុមហ៊ុននាំចេញទំនិញ Phuc Sinhរបស់វៀតណាមបានអះអាងថា រូបលោកបានចំណាយពេលច្រើនថ្ងៃហើយ ក្នុងការទាក់ទងទៅកាន់អតិថិជននៅក្នុងប្រទេសរុស្ស៊ី និងអឺរ៉ុប ដើម្បីដោះស្រាយបញ្ហាការបញ្ជាទិញ និងការនាំចេញពន្យារពេល។ ក្រុមហ៊ុនលោកមានការនាំចេញផលិតផលកាហ្វេ ម្រេច និងផលិតផលផ្សេងៗទៀតទៅរុស្ស៊ីក្នុងតម្លៃប្រហែល ៣០លានដុល្លារក្នុងមួយឆ្នាំ ប៉ុន្តែឥឡូវនេះ ការបញ្ជាទិញទំនិញពីក្រៅប្រទេសរបស់ក្រុមហ៊ុនលោកក៏ត្រូវបានផ្អាកផងដែរ។ ក្រុមហ៊ុនដែលជាដៃគូរបស់លោកនៅរុស្ស៊ី និងអឺរ៉ុបក៏ប្រឈមនឹងបញ្ហាស្រដៀងគ្នានេះដែរ ដោយសារតែទណ្ឌកម្មដាក់លើរុស្ស៊ី។ ក្រៅពីនេះ ក្រុមហ៊ុននាំចេញផ្លែឈើ និងបន្លែរបស់វៀតណាមទៅកាន់រុស្ស៊ី ក៏ត្រូវផ្អាកការបញ្ជាទិញ ដោយសារការដឹកជញ្ជូនជួបការលំបាក។ ក្រុមហ៊ុនដឹកជញ្ជូនអន្តរជាតិ គឺមិនអាចទទួលបានទំនិញអ្វីទាំងអស់ ដោយសារតែមានការរឹតត្បិតជើងហោះហើរទៅកាន់រុស្ស៊ី ការបញ្ជាទិញត្រូវបានពន្យារពេល ហើយការទូទាត់គឺមិនអាចធ្វើទៅបានឡើយដោយសារតែធនាគាររុស្ស៊ី ត្រូវបានដកចេញពីប្រព័ន្ធទូទាត់សកល SWIFT។

ប្រទេសវៀតណាម កាលពីឆ្នាំ២០២១ បាននាំចេញទំនិញទៅកាន់រុស្ស៊ីក្នុងតម្លៃជាង៣ពាន់លានដុល្លារ ហើយការនាំចូលមកវិញមានជាង២ពាន់លានដុល្លារ។ វៀតណាមនាំចេញទំនិញភាគច្រើនទៅរុស្ស៊ីរួមមាន កុំព្យូទ័រ គ្រឿងបង្គុំ ទូរស័ព្ទ វាយនភណ្ឌ កាហ្វេ និងផលិតផលគ្រឿងអេឡិចត្រូនិក។ ដោយឡែក ទំហំពាណិជ្ជកម្មរវាងវៀតណាម និងអ៊ុយក្រែនវិញ គឺមានក្នុងរង្វង់ក្រោម១ពាន់លានដុល្លារប៉ុណ្ណោះ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២។*

## សេដ្ឋកិច្ចសកល

## កាលពីខែកុម្ភៈ ចំនួនអ្នកមានការងារធ្វើនៅសហរដ្ឋអាមេរិកបានកើនឡើងចំនួន ៦៧៨ ០០០កន្លែង



*រូបថត៖ CNBC*

ចំនួនអ្នកមានការងារធ្វើនៅសហរដ្ឋអាមេរិកនៅក្នុងខែកុម្ភៈកើនឡើង ៦៧៨ ០០០កន្លែង នាំឱ្យអត្រាអ្នកអត់ការងារធ្វើធ្លាក់ចុះពី ៤% នៅក្នុងខែមករាមកនៅត្រឹម ៣,៨%។ សេដ្ឋវិទូរបស់ Dow Jones រំពឹងថាកំណើនការងារនៅសហរដ្ឋអាមេរិកនឹងអាចកើនឡើងដល់ ៤៤០ ០០០កន្លែង។ ទន្ទឹមនឹងនេះអត្រានៃការចូលរួមរបស់កម្លាំងពលកម្មនៅក្នុងទីផ្សារការងារ ដែលបង្ហាញពីចំនួនមនុស្សពេញវ័យដែលកំពុងធ្វើការ ឬកំពុងស្វែងរកការងារធ្វើបានកើនឡើងពី ៦២,៣% ទៅ ៦៣,២%។ ចំណែកឯកំណើននៃប្រាក់ឈ្នួលវិញកើនឡើងតាំងពីខែមុន ប៉ុន្តែបានធ្លាក់ចុះបន្តិចពី៥,៧%ក្នុងខែមករាមកនៅត្រឹម៥,១%។ ទោះជាយ៉ាងណាសេដ្ឋវិទូ Nick Bunker រំពឹងថាកំណើនប្រាក់ឈ្នួលនឹងបន្តកើនឡើងខ្លាំង។ ខណៈដែលសេដ្ឋវិទូ Daniel Zhao បានព្យាករណ៍ឃើញថា ល្បឿននៃកំណើនប្រាក់ឈ្នួលនឹងចាប់ផ្ដើមធ្លាក់ចុះនៅពេលណាមួយក្នុងឆ្នាំនេះ។ ទោះយ៉ាងណានៅក្នុងឆ្នាំ២០២២នេះកំណើនប្រាក់ឈ្នួលនឹងបន្តកើនឡើងក្នុងកម្រិតមធ្យម ព្រោះតម្រូវការកំលាំងពលកម្មលើសពីការផ្គត់ផ្គង់។ ប៉ុន្តែលោកបានលើកឡើងថាចំពោះកម្មករវិញ ការកើនឡើងនៃប្រាក់ឈ្នួលគឺជាកំណើនអវិជ្ជមាន ព្រោះអត្រាអតិផរណាហក់ឡើងខ្ពស់ ពោលពីមួយឆ្នាំទៅមួយឆ្នាំ អត្រាអតិផរណាបានកើនឡើងដល់ទៅ ៦០០%។ ដោយឡែកលោក Giacomo Santangelo ដែលជាសេដ្ឋវិទូរបស់ក្រុមហុន Monster បានលើកឡើងយ៉ាងដូច្នេះថា ទោះបីជាប្រាក់ឈ្នួលកើនឡើងនៅក្នុងកម្រិតណាក៏ដោយ លោករំពឹងថា នាពេលអនាគតកំណើននៃប្រាក់ឈ្នួលនឹងអាចតាមទាន់កំណើនអតិផរណា។

ចំណែកឯលោកប្រធានាធិបតី ចន បៃឌិន ឯណោះវិញយល់ឃើញថា កំណើនការងារគឺជាសញ្ញាវិជ្ជមានមួយដែលបង្ហាញថា ទីផ្សារការងារនៅសហរដ្ឋអាមេរិកកំពុងតែងើបឡើងវិញ។ ទោះយ៉ាងណាការកើនឡើងនៃអត្រាអតិផរណាកំពុងតែដាក់សំពាធលើប្រជាពលរដ្ឋអាមេរិក។ ដូចនេះការកាត់បន្ថយថ្លៃគឺជាគោលដៅចំបងរបស់រដ្ឋាភិបាលលោក។ គួរកត់សំគាល់ថា នៅក្នុងឆ្នាំ២០២០ ទំហំប្រាក់ខែមានការកើនឡើងខ្លាំង ជាពិសេសនៅក្នុងវិស័យដែលទទួលបានប្រាក់ខែទាបបំផុតដូចជា៖ អ្នកធ្វើការនៅក្នុងវិស័យភោជនីយដ្ឋាន សណ្ឋាគារ ហាងលក់ទំនិញ និងកម្មករធ្វើការក្នុងឃ្លាំងជាដើម។ ទោះយ៉ាងណាអ្នកឃ្លាំមើលកំលាំងពលកម្មផ្តល់យោបល់ថា ប្រសិនបើប្រាក់ឈ្នួលកើន ប៉ុន្តែប្រសិទ្ធផលការងារមិនកើននោះនឹងបង្កឱ្យមានបញ្ហា។ បើយោងតាមទិន្នន័យផលិតភាពការងារនៅសហរដ្ឋអាមេរិកកើនឡើងចំនួន ៦,៦% នៅក្នុងត្រីមាសទី៤ កាលពីឆ្នាំ២០២១ ជាមួយនឹងអត្រាកំណើនទិន្នផលការងារចំនួន ៩,១% ។ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី៤ ខែមិនា ឆ្នាំ២០២២*

## ប្រេងឡើងថ្លៃបានធ្វើឱ្យប៉ះពាល់ដល់ទំនិញជាច្រើនពាន់មុខ



*រូបថត៖ CNBC*

តម្លៃហ្គាសនៅសហរដ្ឋអាមេរិកកើនឡើងប្រហែលជា ៥សេនក្នុងមួយហ្គាលុងរហូតដល់ ៤,០៦៥ដុល្លារក្នុងរ

យៈពេលត្រឹមតែមួយយប់ប៉ុណ្ណោះ។ ដោយសារតែសហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មប្រេងរបស់រុស្ស៊ី នាំឱ្យតម្លៃប្រេងឆៅរបស់ West Texas Intermediate ដែលជាតម្លៃស្តង់ដាររបស់សហរដ្ឋអាមេរិកកើនឡើងដល់ ១២០ដុល្លារក្នុងមួយបារ៉ែល។ ការកើនឡើងនៃតម្លៃប្រេងនេះបានធ្វើឱ្យតម្លៃទំនិញប្រើប្រាស់ប្រចាំថ្ងៃ និងផលិតផលប្រើប្រាស់ប្រចាំគ្រួសារកើនឡើងរាប់ពាន់មុខចាប់តាំងពីផលិតផលមីក្រូហ្វេបឺ រហូតដល់ផលិតផលផ្តល់សំណើមដល់ស្បែក និងថ្នាំពេទ្យជាដើម។ លោក Patrick DeHaan ប្រធានក្រុមអ្នកវិភាគប្រេងរបស់ GasBuddy.com បាននិយាយថា ប្រេងឥន្ធនៈគឺជាវត្ថុធាតុដែលសំខាន់សម្រាប់ប្រើប្រាស់ ដើម្បីផលិតផលិតផលជាច្រើនមុខតាំងពីគ្រឿងសំអាងរហូតដល់ផលិតផលប្លាស្ទិក និងជីជាដើម។ ដូចនេះ ប្រសិនបើជីឡើងថ្លៃនោះគ្រាប់ធញ្ញជាតិក៏នឹងឡើងថ្លៃដែរ។ ជាពិសេសផលិតផលកសិកឧស្សាហកម្ម និងចំណីអាហារ ហើយផលប៉ះពាល់នេះក៏នឹងធ្វើឱ្យផលិតផលផ្នែកឧស្សាហកម្មថែរទាំងសុខភាពឡើងថ្លៃដែរ។ ក្រៅពីនោះ សម្ភារៈសំណង់ និងគ្រឿងចក្រដែលប្រើប្រាស់នៅក្នុងការសាងសង់អគារក៏នឹងឡើងថ្លៃដែរ។ ជារួម ៦០% នៃប្រេងរបស់ពិភពលោកត្រូវបានប្រើប្រាស់នៅក្នុងទម្រង់ជាប្រេងឥន្ធនៈ។ សល់ពីនោះវាត្រូវបានរួមបញ្ចូលទៅក្នុងតម្លៃនៃផលិតផលជាច្រើនមុខ និងទំនិញប្រើប្រាស់ប្រចាំគ្រួសារ ដែលភាគច្រើនផលិតផលទាំងនោះពុំប្រើប្រាស់ប្រេងដោយផ្ទាល់នោះទេ។ សរុបមក តម្លៃទំនិញស្ទើរគ្រប់មុខទាំងអស់សុទ្ធតែបណ្តាលមកពីការឡើងថ្លៃប្រេង៕ *ដោយ **វង្ស ច័ន្ទរស្មីដារា***

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី០៨ ខែមិនា ឆ្នាំ២០២២*

## ប្រទេសចិនប្រកាសប្តេជ្ញាបន្តការបង្រ្កាបលើការអនុវត្តអាជីវកម្មផ្តាច់មុខ




*ដោយ ខេមបូណ្ឌមីស*

នាយករដ្ឋមន្ត្រីចិនបានអះអាងថា នឹងបង្រ្កាបលើអាជីវកម្មរកស៊ីផ្តាច់មុខ។ កន្លងមករដ្ឋអំណាចចិន បានចាត់វិធានការបង្រ្កាបយ៉ាងចាស់ដៃទៅលើក្រុមហ៊ុនធំៗរបស់ខ្លួន។ នាពេលថ្មីៗនេះ រដ្ឋាភិបាលទីក្រុងប៉េកាំង បានបង្រ្កាបលើឧស្សាហកម្មដែលរាប់ចាប់ពីពាណិជ្ជកម្មអេឡិចត្រូនិករហូតដល់ការអប់រំឯកជន ដែលទីក្រុងប៉េកាំងចាត់ទុកថា ការបង្រ្កាបនេះជាសកម្មភាពដែលបានធ្វើឱ្យទីផ្សារពិភពលោកកាន់តែរីកចម្រើន នឹងក៏បន្តធ្វើឱ្យកាន់តែប្រសើរឡើងនូវច្បាប់បទប្បញ្ញត្តិបន្ថែមទៀត។ ប្រទេសចិននឹងអនុវត្តបន្ថែមទៀត ដើម្បីធានាឱ្យមានការប្រកួតប្រជែងដោយស្មើភាព និងចាត់វិធានការកាន់តែខ្លាំងប្រឆាំងនឹងអាជីវកម្មផ្តាច់មុខ និងការប្រកួតប្រជែងមិនយុត្តិធម៌ ដើម្បីធានាបាននូវបរិយាកាសទីផ្សារដែលមានសណ្តាប់ធ្នាប់ និងយុត្តិធម៌។ ប្រទេសចិននឹងធ្វើសកម្មភាពយ៉ាងឆាប់រហ័ស ដើម្បីកែលម្អវិធានបទប្បញ្ញត្តិសម្រាប់ឧស្សាហកម្មសំខាន់ៗ វិស័យដែលកំពុងរីកចម្រើន និងវិស័យដែលមានការចូលរួមពីបរទេស ហើយដាក់ចេញនូវវិធានការថ្មី ដើម្បីធ្វើឱ្យការដាក់ចេញនូវបទប្បញ្ញត្តិបានកាន់តែចំគោលដៅ និងមានប្រសិទ្ធភាពជាងមុន។

ដោយឡែក នៅក្នុងវិធានការគាំទ្រវិញ រដ្ឋាភិបាលចិនបាននិយាយថា ខ្លួននឹងបង្កើនការគ្រប់ដណ្តប់លើការកាត់ពន្ធសម្រាប់សហគ្រាសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ធុនតូច និងមធ្យមពី ៧៥% ទៅ ១០០% និងគាំទ្រការវិនិយោគបរទេសបន្ថែមទៀត នៅក្នុងការផលិតកម្រិតមធ្យម និងកម្រិតខ្ពស់ ព្រមទាំងការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D)ជាដើម។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលទីក្រុងប៉េកាំងនឹងជំរុញឱ្យមានការដាក់ឱ្យដំណើរការទ្រង់ទ្រាយធំនៃបណ្ដាញ 5G ផងដែរ។

សូមបញ្ជាក់ថា នៅប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋអំណាចក្រុងប៉េកាំងបានចេញនូវបទប្បញ្ញត្តិថ្មីៗជាច្រើន ដើម្បីបង្ក្រាបលើក្រុមហ៊ុនបច្ចេកវិទ្យាធំៗ ដូចជាក្រុមហ៊ុន Alibaba និង Ant Group របស់មហាសេដ្ឋីជេកម៉ា និងក្រុមហ៊ុនជាច្រើនទៀត ដូចជា Tencent, Didi, រួមទាំងក្រុមហ៊ុន Byte dance ដែលជាក្រុមហ៊ុនមេរបស់ Tiktok ផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។*

## តើអាជីវកម្មអាមេរិកនឹងចិនជួបភាពអាប់អួរកម្រិតណា ចំពេលរដ្ឋាភិបាលប្រទេសទាំងពីរមានភាពតានតឹងកើនឡើង?



*ដោយ ខេមបូណ្ឌមីស*

ធុរកិច្ច មានភាពតានតឹងកាន់តែខ្លាំងឡើងរវាងសហរដ្ឋអាមេរិក និងចិននៅក្នុងអាជីវកម្មកំពូលៗនោះគឺដោយសារតែច្បាប់មិនស៊ីចង្វាក់គ្នា និងមិនមានភាពច្បាស់លាស់រវាងរដ្ឋាភិបាលទាំងពីរនេះ។ កំណើននៃភាពជឿជាក់ទៅទីផ្សារក្នុងស្រុកនៅប្រទេសចិនបានធ្លាក់ចុះ ១១% ធៀបនឹងឆ្នាំមុន។

ប្រធានសភាពាណិជ្ជកម្មអាមេរិកក្នុងប្រទេសចិន បាននិយាយថា អាជីវកម្មអាមេរិកនៅក្នុងប្រទេសចិន មានភាពអាប់អួរខ្លាំង គឺក្រោយការបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាមេរិកលោកចូបៃឌិនមកម្ល៉េះ។ ក្នុងនោះក្រុមហ៊ុនដែលប្រតិបត្តិការក្នុងប្រទេសចិន គឺមានផលលំបាកក្នុងការជួលអ្នកមានទេពកោសល្យពីបរទេស និងក្នុងស្រុក ដោយសារវិធានការរឹតបន្តឹងកូវីត១៩នៅក្នុងប្រទេសចិន សម្រាប់បុគ្គលិកពីបរទេស ពិបាកធ្វើដំណើរមកធ្វើការនៅក្នុងប្រទេសចិន។ ដោយឡែកអ្នកមានទេពកោសល្យរបស់ចិនជាច្រើននៅក្នុងស្រុក គឺមិនធ្វើការឱ្យក្រុមហ៊ុនអាមេរិកឡើយ។ ទន្ទឹមនឹងនេះ ផលិតផលម៉ាកពីអាមេរិក ក៏បានចាប់ផ្ដើមបាត់បង់តម្លៃនៅទីផ្សារចិនដែរ ដោយសារតែភាពតានតឹងនៅក្នុងទំនាក់ទំនងទ្វេភាគីរវាងប្រទេសចិន និងអាមេរិក។ ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចចិនក៏បានបង្ហាញពីបញ្ហាប្រឈមទាំងសម្រាប់ក្រុមហ៊ុនចិននិងក្រុមហ៊ុនអាមេរិកក្នុងប្រទេសចិន។

ទោះបីជាមានបញ្ហាប្រឈមក៏ដោយ ការស្ទង់មតិបានបង្ហាញថា ក្រុមហ៊ុនភាគច្រើន គ្រោងនឹងពង្រីកខ្លួនបន្ថែម ដោយបង្កើនការវិនិយោគនៅក្នុងប្រទេសចិននៅឆ្នាំ ២០២២៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។*

## វិស័យកសិកម្មការរបស់រុស្ស៊ីត្រូវជាប់គាំង ដោយសារវិទណ្ឌកម្មពីលោកខាងលិច



*ដោយ ខេមបូណ្ឌមីស*

វិស័យភស្តុភារ (Logistic)នៅក្នុងប្រទេសរុស្ស៊ីកំពុងដំណើរការយ៉ាងរដាក់រដុប ហើយក៏នឹងអាចឈប់ដំណើរការផងដែរ ក្រោយពេលដែលសហរដ្ឋអាមេរិក និងអឺរ៉ុបបានដាក់ទណ្ឌកម្មកាន់តែធ្ងន់ធ្ងរ តាមរយៈការរារាំងការនាំចូលផលិតផល និងគ្រឿងបន្លាស់ ក៏ដូចជាការនាំចេញធនធានកម្រ និងគ្រាប់ធញ្ញជាតិពីរុស្ស៊ី។ ទណ្ឌកម្មពីលោកខាងលិច កំពុងធ្វើឱ្យសេដ្ឋកិច្ចរុស្ស៊ីកំពុងតែឯកោពីពិភពលោកទាំងមូល។ អាជ្ញាធរគយនៃសមាជិកសហភាពអឺរ៉ុប កំពុងហាមឃាត់នាវាដឹកទំនិញជាប់ព្រំដែនប្រទេសរុស្ស៊ីពីការប្រើប្រាស់កំពង់ផែរបស់អឺរ៉ុប ជាពិសេសបញ្ឈប់ផ្លូវសមុទ្រដែលប្រើសម្រាប់ដឹកជញ្ជូនកុងតឺន័រជាច្រើនដែលត្រូវបានដឹកជញ្ជូនទៅកាន់ប្រទេសរុស្ស៊ី។ ប្រទេសជាច្រើនក្នុងតំបន់អឺរ៉ុប ក៏បានប្រកាសបិទការទទួលទិញទំនិញ និងបញ្ឈប់ការដឹកកុងតឺន័រទាំងទៅ និងមកពីប្រទេសរុស្ស៊ីផងដែរ។ ការដឹកជញ្ជូនតាមផ្លូវអាកាសក៏រងការប៉ះពាល់ ដោយសារតែសហភាពអឺរ៉ុបបានហាមឃាត់យន្តហោះរុស្ស៊ីមិនឱ្យហោះហើរពីលើដែនអាកាសរបស់សហភាពអឺរ៉ុប។ ដូច្នេះរុស្ស៊ីនឹងគ្មានជម្រើសអ្វីក្រៅពីពឹងផ្អែកលើការដឹកជញ្ជូនតាមរថភ្លើងឆ្លងកាត់ស៊ីបេរី និងតាមផ្លូវគោកពីប្រទេសចិននោះទេ។ ជីវភាពរស់នៅរបស់ប្រជាជនរុស្ស៊ីចាប់ផ្តើមរងផលប៉ះពាល់ដោយសារកង្វះទំនិញនៅក្នុងប្រទេសរុស្ស៊ីត្រូវបានគេរំពឹងថានឹងកាន់តែធ្ងន់ធ្ងរទៅៗ នៅពេលខាងមុខនេះ។

គួរឱ្យកត់សម្គាល់ថា ការធ្លាក់ចុះនៃការនាំចេញធនធានកម្រ និងគ្រាប់ធញ្ញជាតិពីប្រទេសរុស្ស៊ីអាចនាំឱ្យតម្លៃវត្ថុធាតុដើមកាន់តែខ្ពស់ ដែលវានឹងដាក់បន្ទុកលើក្រុមហ៊ុន និងអ្នកប្រើប្រាស់ជុំវិញពិភពលោក ដូច្នេះផលប៉ះពាល់លើសេដ្ឋកិច្ចពិភពលោកក៏នឹងកើនឡើងខ្ពស់ដូចគ្នាផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*<u>ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។</u>*

## ធនាគាររុស្ស៊ីប្តូរមកប្រើប្រព័ន្ធកាត UnionPayរបស់ចិន ក្រោយVisa និង MasterCard បិទប្រតិបត្តិការនៅរុស្ស៊ី




*ដោយ ខេមបូណូមីស*

ធនាគាររុស្ស៊ីជាច្រើន បានបញ្ជាក់ថា ឆាប់ៗនេះ ពួកគេបានចាប់ផ្តើមដាក់ឱ្យដំណើរការប្រព័ន្ធប្រតិបត្តិការកាត UnionPay របស់ចិន ជាមួយនឹងបណ្តាញ Mir ដែលគ្រប់គ្រងដោយរុស្ស៊ីផ្ទាល់ បន្ទាប់ពីក្រុមហ៊ុន Visa និង MasterCard របស់អាមេរិក នឹងផ្អាកប្រតិបត្តិការរបស់ខ្លួននៅរុស្ស៊ី ដោយសារតែសង្គ្រាមនៅអ៊ុយក្រែន។

ប្រព័ន្ធធនាគាររបស់រុស្ស៊ី ត្រូវបានរងទណ្ឌកម្មជាបន្តបន្ទាប់នៅក្រោយពេលរុស្ស៊ីបានធ្វើការឈ្លានពានអ៊ុយក្រែន។ ទណ្ឌកម្មថ្មីចុងក្រោយនេះ គឺក្រុមហ៊ុន Visa និង MasterCard របស់អាមេរិកបានប្រកាសនឹងបិទប្រតិបត្តិការរបស់ខ្លួនទាំងអស់នៅរុស្ស៊ី ដែលកំពុងធ្វើឱ្យធនាគាររុស្ស៊ីកំពុងខ្វះខ្វែងរកដំណោះស្រាយបន្ទាន់សម្រាប់អ្នកប្រើប្រាស់របស់ខ្លួន។ ធនាគារធំៗរបស់រុស្ស៊ីដូចជា Sberbank, Alfa Bank និង Tinkoff បានប្រកាសថា ពួកគេនឹងប្តូរមកប្រើប្រព័ន្ធទូទាត់ កាត UnionPay របស់ចិនជំនួសឱ្យការប្រើប្រាស់ VISA និង MasterCard របស់អាមេរិក។

ក្រុមហ៊ុន Visa បានបញ្ជាក់ថា ប្រតិបត្តិការទាំងអស់ដែលជាប់ទាក់ទងនឹងរុស្ស៊ី នឹងមិនដំណើរទៀតនោះទេ។ ការផ្អាកប្រតិបត្តិការរបស់ក្រុមហ៊ុនទាំងពីរនេះ គឺវា

អាចនឹងបង្កការរំខានបន្ថែមទៀត សម្រាប់ពលរដ្ឋរុស្ស៊ី ដែលកំពុងតែទទួលរងនូវអតិផរណាកើនឡើង ក៏ដូចជាផលវិបាកនៃសេដ្ឋកិច្ច និងការធ្លាក់ចុះទំនិញនាំចេញនាំចូលជាដើម។ ក្រៅតែពីក្រុមហ៊ុន VISA និង Mastercard ក៏មានដែរក្រុមហ៊ុន Paypal ដែលជាក្រុមហ៊ុនហិរញ្ញវត្ថុ និងអេឡិចត្រូនិកដ៏ធំមួយដែរនោះ ក៏បានប្រកាសផ្អាកប្រតិបត្តិការរបស់ខ្លួននៅរុស្ស៊ីដែរ។ ធនាគារ Sberbank ដែលជាធនាគារផ្តល់កម្ចីដ៏ធំបំផុតរបស់រុស្ស៊ី បានអះអាងថា ការបិទប្រតិបត្តិការរបស់ VISA និង Mastercard នឹងមិនធ្វើឱ្យប៉ះពាល់ដល់អ្នកប្រើប្រាស់នៅរុស្ស៊ីនោះទេ។ អ្នកប្រើប្រាស់រុស្ស៊ី នៅតែអាចដកលុយ ផ្ទេរប្រាក់ និងទូទាត់ថ្លៃទំនិញតាមហាងទាំងនៅលើ Online និង Offline ពីព្រោះថា ប្រតិបត្តិការនៅក្នុងប្រទេសរុស្ស៊ី គឺធ្វើឡើងតាមរយៈប្រព័ន្ធទូទាត់កាតរបស់ជាតិនៅក្នុងស្រុក ដែលមិនពឹងផ្អែកលើប្រព័ន្ធទូទាត់បរទេសឡើយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៤ ខែមីនា ឆ្នាំ២០២២

- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសបារាំងបានបន្ត ក្នុងខែធ្នូ ឆ្នាំ 2021
- អតិរេកពាណិជ្ជកម្មរបស់រុស្ស៊ីបានកើនឡើង ក្នុងខែធ្នូ ឆ្នាំ 2021

ថ្ងៃអង្គារ ទី១៥ ខែមីនា ឆ្នាំ២០២២

- កំណើនអត្រានីកម្មភាព នៅទីក្រុង កើនឡើងដល់ 5.1%នៅក្នុងខែធ្នូ ឆ្នាំ 2021
- អត្រាគ្មានការងារធ្វើរបស់ចក្រភពអង់គ្លេស នៅក្នុងត្រីមាសទី 4 ឆ្នាំ 2021 ដែលនៅសេសសល់ក្នុងកម្រិតទាបបំផុត

ថ្ងៃពុធ ទី១៦ ខែមីនា ឆ្នាំ២០២២

- អត្រានីកម្មភាព តាមរដូវកាលនៅក្នុងប្រទេសកូរ៉េខាងត្បូងបានប្រសើរឡើងដល់ 3.6% ក្នុងខែមករា ឆ្នាំ 2022 ពី 3.8% ក្នុងខែមុន
- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសជប៉ុនបានកើនឡើងយ៉ាងខ្លាំង ក្នុងខែមករា ឆ្នាំ 2022

ថ្ងៃព្រហស្បតិ៍ ទី១៧ ខែមីនា ឆ្នាំ២០២២

- អត្រានីកម្មភាព តាមរដូវកាលរបស់ប្រទេសអូស្ត្រាលីមានចំនួន 4.2% ក្នុងខែមករា ឆ្នាំ 2022
- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសអេស្ប៉ាញក្នុងខែធ្នូ ឆ្នាំ 2021

ថ្ងៃសុក្រ ទី១៨ ខែមីនា ឆ្នាំ២០២២

- តំបន់ចាយប្រាក់អឺរ៉ូបានប្រកាសឱនភាពពាណិជ្ជកម្មចំនួន 4.6 ពាន់លានអឺរ៉ូនៅក្នុងខែធ្នូ ឆ្នាំ 2021
- តម្លៃនៃប្រាក់កម្ចីនៅក្នុងប្រទេសឥណ្ឌូនេស៊ីបានកើនឡើង 5.80% នៅក្នុងខែមករាឆ្នាំ 2022 ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន៕